ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ ភ្នំពេញ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤៩១

ចុះថ្ងៃទី : ១៧-០៩-០៨

សាលដីកា

លេខ : ០៩ "ខ"

ចុះថ្ងៃទី : ២៩-០១-១០

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១០ ដោយមានសមាសភាពដូចខាងក្រោម

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៩១ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ រវាង

- ជនជាប់ចោទឈ្មោះ [redacted] ស៊ិយ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ កើតនៅ ភូមិជីងរ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅមុនចាប់ខ្លួន [redacted] ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ឃុំខ្លួនថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៧ បច្ចុប្បន្ននៅក្នុងពន្ធនាគារខេត្តព្រះសីហនុ។

- ត្រូវជាប់ចោទពីបទ : " រំលោភសេពសន្ថវៈ " ប្រព្រឹត្តនៅ ភូមិស្ទាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ជនរងគ្រោះឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅក្រុម ១៣ ភូមិស្ទាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៥១ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ិយ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥ "ខ" ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ត្រង់ចំណុចទាំងមូល ។៚

## ដំណើររឿងមានដូចតទៅ

កាលពីយប់ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ឈ្មោះ[redacted] ស៊ុយ ទៅស៊ីផឹកនៅផ្ទះឈ្មោះ ភាព នៅភូមិស្នាច់ដែង តាំងពីព្រលប់រហូតម៉ោង ៨យប់ ដំណាលគ្នានោះដែរឈ្មោះ[redacted]ស៊ីណា បានទៅទិញថ្នាំពេទ្យ ក៏ចូលទៅលេងផ្ទះភាព ហើយក៏ពឹង ភាព ឱ្យជូនទៅផ្ទះ នៅម្តុំចៃឆ្កែ ដែលមានចំងាយជាង ១០០០ម៉ែត្រ ពីផ្ទះភាព។ ធ្វើដំណើរបានជាងពាក់កណ្តាលផ្លូវ ភាព ក៏ត្រលប់មកផ្ទះវិញ។ ពេលនោះ[redacted] ស៊ុយ ក៏ឆក់ឱកាសស្ទុះទៅជួប [redacted]ស៊ីណា បានចាប់អោប និងផ្តួលលើដី។[redacted] ស៊ីណា រើបំរះដែរតែត្រូវ [redacted] ស៊ុយ ចាប់សំរាតខោរំលោភបានសំរេចតែម្តង នៅចំណុចចៃឆ្កែ ឃុំស្នាច់ដែង [redacted]ស៊ីណា ទៅប្តឹងប៉ូលីស ចាប់ខ្លួនភ្លាមតែម្តង។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥ "ខ" ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

១. ផ្តន្ទាទោសលើឈ្មោះ [redacted] ស៊ុយ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ (ដប់) គិតពីថ្ងៃឃុំខ្លួន ២៥ ខែ សីហា ឆ្នាំ ២០០៧។

ពីបទ " រំលោភសេពសន្ថវៈ " ប្រព្រឹត្តនៅភូមិស្នាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហ៊ានុ កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. វត្ថុតាង ខោជើងវែងពណ៌ស ផ្កាអុចខ្មៅ១ចំនួនមួយ, អាវយឺតដៃខ្លីពណ៌ផ្កាឈូកចំនួនមួយ និង ខោស្លីបពណ៌ស ចំនួនមួយ រឹបអូសប្រគល់អោយឈ្មោះ[redacted]ស៊ីណា វិញ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ចំពោះមុខជនជាប់ចោទ មេធាវីអោយជនជាប់ចោទ និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។ ទុកសិទ្ធិអោយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥១ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨ របស់ជនជាប់ចោទឈ្មោះ[redacted]ស៊ុយ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥ "ខ" ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ត្រង់ចំណុចទាំងមូល។
- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍
- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍

## ដំណើរសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ និង ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ[redacted] ស៊ីណា បានឆ្លើយនៅសាលាដំបូងក្រុងព្រះសីហនុ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១. តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ ថាខ្លួនពិតជាបានចាប់ជនរងគ្រោះផ្តួលទៅលើដី ហើយបានប្រព្រឹត្តរំលោភសេពសន្ថវៈរហូតបានសំរេច។ មានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted]ស៊ុយ ពីបទ រំលោភសេពសន្ថវៈ

តាមមាត្រា ០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥ "ខ" ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ទុកជាបានការ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ដោយមូលហេតុថា កូនក្តីរបស់ខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកទី០១ សុំទៅក្រុមមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង ។

- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា រំពឹកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា

១. បណ្តឹងឧទ្ធរណ៍លេខ ៥១ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] ស៊ុយ ជាជនជាប់ចោទធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២. ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ប្រមាណម៉ោង ៨,៣០នាទី ខ្លួនពិតជាបានចាប់រំលោភសេពសន្ថវៈលើជនរងគ្រោះប្រាកដមែន ដោយពេលនោះជនរងគ្រោះបានពឹងឱ្យឈ្មោះ [redacted] យូន ជូនទៅម៉ុំចៃផ្លែ ខ្លួនដឹងក៏ដើរតាមពីក្រោយ ដល់ពាក់កណ្តាលផ្លូវ ខ្លួនឱ្យយាយយូនត្រលប់ទៅវិញ ។ លុះ[redacted] យូន ទៅផុតខ្លួនក៏ចាប់ជនរងគ្រោះរំលោភបានសម្រេច ។

៣. មានពិរុទ្ធលើជនជាប់ចោទ ពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្ទាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ បទល្មើសមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១៥ " ខ " ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥១ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] ស៊ុយ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២. តម្កល់សាលក្រមលេខ ១៥ "ខ" ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ របស់សាលាដំបូងក្រុងព្រះសីហនុ ទុកជាបានការទាំងមូល ។

៣. បង្គាប់ឱ្យបន្តនូវការឃុំខ្លួនជនជាប់ចោទ ៚

សាលដីកានេះ ជំនុំជម្រះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារ ជនជាប់ចោទ កំបាំងមុខដើមបណ្ដឹង, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៥

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

........................................................................................................................................................

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤ |
| [redacted] | ក្រឡាបញ្ជី |